ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខៈ ៧៩៥៧ ស.ជ.ណ.ររក

ថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

# សេចក្ដីជូនដំណឹង
## ស្ដីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

កាលពីថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី មានរៀបចំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីពិនិត្យនិងពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្ដីព្រាងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០២៤-២០២៨។
២- សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល។
៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស។

### ១- សេចក្ដីព្រាងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០២៤-២០២៨

គណៈរដ្ឋមន្ត្រីបានសម្រេច៖

១.១- ឯកភាពលើសេចក្ដីព្រាងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០២៤-២០២៨ ដែលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានស្នើឡើងមកនេះ។

១.២- ប្រគល់ភារកិច្ចជូនឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី បញ្ចប់នីតិវិធីសេសសល់ ដើម្បីដាក់អនុវត្ត និងផ្សព្វផ្សាយផែនការសកម្មភាពនេះ ក្នុងពេលឆាប់ៗខាងមុខ។

១.៣- ប្រគល់ភារកិច្ចជូនឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឯកឧត្តម **ថៅ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រៀមលក្ខណៈក្នុងការដាក់ចេញនូវកិច្ចអន្តរាគមន៍ជាបន្ទាន់និងទាន់ពេលដល់ប្រជាកសិករ ប្រសិនបើមានគ្រោះមហន្តរាយកើតឡើង ជាពិសេស គ្រោះទឹកជំនន់ ដើម្បីធានាថា ប្រជាកសិករយើងអាចបង្កបង្កើនផលក្នុងរដូវវស្សានេះប្រកបដោយប្រសិទ្ធភាពនិងទិន្នផលខ្ពស់។

១.៤- ប្រគល់ភារកិច្ចជូនឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឯកឧត្តម **ថៅ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងរដ្ឋបាលថ្នាក់ក្រោមជាតិ បន្តពង្រឹងនិងពន្លឿនបន្ថែមនូវការងាររៀបចំប្រព័ន្ធរំដោះទឹកជំនន់ ជាពិសេសពីជំនន់ទឹកភ្លៀង ចំពោះទីតាំងសំខាន់ៗដែលមានសក្តានុពលសេដ្ឋកិច្ច ហើយងាយរងគ្រោះ។

១.៥- ប្រគល់ភារកិច្ចជូនឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ពន្លឿនការរៀបចំការធ្វើបច្ចុប្បន្នភាព និងការពង្រីកទៅកាន់បណ្តាសហគមន៍ នូវប្រព័ន្ធប្រកាសឱ្យដឹងមុននូវគ្រោះអាសន្ននិងគ្រោះមហន្តរាយគ្រប់ប្រភេទ ទាំងគ្រោះមហន្តរាយដែលបណ្តាលពីធម្មជាតិ ដូចជា គ្រោះទឹកជំនន់ ខ្យល់ព្យុះ និងជំងឺរាតត្បាត ក៏ដូចជាគ្រោះមហន្តរាយដែលបណ្តាលពីឧបទ្ទវហេតុផ្សេងៗ ដូចជា អគ្គិភ័យ និងគ្រោះថ្នាក់ ចរាចរណ៍ជាដើម។

១.៦- ប្រគល់ភារកិច្ចជូនឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពង្រឹងកិច្ចសហការក្នុងការចុះអន្តរាគមន៍ដល់ប្រជាជនរងគ្រោះដោយការផ្ទុះឡើងនូវសត្វល្អិតចង្រៃ ដែលកំពុងបង្កផលប៉ះពាល់លើផ្ទៃដីដាំដំណាំ និងត្រូវគិតគូរលើភាពចាំបាច់នៃការផ្តល់ជំនួយ ដូចជា គ្រាប់ពូជឬធនធានចាំបាច់ដទៃទៀត ដល់ប្រជាកសិកររងគ្រោះ ដើម្បីឱ្យពួកគាត់អាចបន្តការដាំដុះឡើងវិញបាន។

១.៧- ប្រគល់ភារកិច្ចជូនក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅតាមខេត្ត ស្រុក ឃុំ ភូមិ ដែលរងគ្រោះពីការផ្ទុះឡើងនូវសត្វល្អិតចង្រៃនេះ ពង្រឹងការចុះទៅទីតាំងរៀងៗខ្លួន ដើម្បីស្វែងយល់ពីប្រជាកសិករនូវផលប៉ះពាល់ជាក់ស្តែងដែលបានកើតឡើង ព្រមទាំងធ្វើអន្តរាគមន៍ជួយតាមលទ្ធភាពជាក់ស្តែង រួចរាយការណ៍និងលើកជាអនុសាសន៍ដាក់លាក់ជូនរាជរដ្ឋាភិបាលតាមការចាំបាច់។

១.៨- ប្រគល់ភារកិច្ចជូនឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័នពាក់ព័ន្ធ គិតគូរលើការរៀបចំផែនការឆ្លើយតបចំពោះគ្រោះមហន្តរាយនៃការផ្ទុះឡើងនូវសត្វល្អិតចង្រៃ ក៏ដូចជាយន្តការចាំបាច់នានា ដើម្បីពង្រឹងជវភាពនៃការឆ្លើយតបទៅនឹងគ្រោះមហន្តរាយឱ្យបានទាន់ពេលដល់ប្រជាកសិករ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងគ្រោះមហន្តរាយប្រភេទនេះ នាពេលអនាគត។

## ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល

គណៈរដ្ឋមន្ត្រីបានសម្រេច៖

២.១- ឯកភាពលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ដែលក្រសួងផែនការបានស្នើឡើងមកនេះ។

២.២- ប្រគល់ភារកិច្ចជូន ឯកឧត្តម **ប៊ិន ត្រាឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី បន្តរៀបចំ និងបញ្ចប់នីតិវិធីពាក់ព័ន្ធ ដើម្បីឱ្យអនុក្រឹត្យនេះ អាចដាក់ចេញអនុវត្តក្នុងពេលឆាប់ៗខាងមុខ ដោយចាត់ទុកជាការប្រញាប់។

២.៣- ប្រគល់ភារកិច្ចជូន ឯកឧត្តម **ប៊ិន ត្រាឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍និងនីតិវិធី ដែលបានចែងក្នុងអនុក្រឹត្យនេះ ដើម្បីវិភាជថវិកាឱ្យចំគោលដៅ ក្នុងស្មារតីសន្សំសំចៃនិងមានប្រសិទ្ធភាពខ្ពស់បំផុត។

២.៤- ប្រគល់ភារកិច្ចជូន ឯកឧត្តម **ប៊ិន ត្រាឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ ក្នុងនាមជាស្ថាប័នវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធ ពង្រឹងការវាយតម្លៃសមិទ្ធកម្មឱ្យបានជាប់ជាប្រចាំ ហើយសហការគ្នាក្នុងការដាក់ចេញនូវវិធានការចាំបាច់ ដើម្បីបង្កើនសមិទ្ធកម្មចំពោះគម្រោងដែលមិនទាន់ឆ្លើយតបទៅនឹងការរំពឹងទុក ព្រមទាំងយកលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្មទាំងនេះ ជាធាតុចូលសម្រាប់ធ្វើបច្ចុប្បន្នភាពឬរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល លើកក្រោយៗ ដើម្បីធានាថាគម្រោងដែលបានគ្រោងឬដាក់ចេញ ពិតជាឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម សេដ្ឋកិច្ច ហើយបម្រើផលប្រយោជន៍ដល់ប្រជាជនយ៉ាងពិតប្រាកដ។

## ៣- បញ្ហាផ្សេងៗ

គណៈរដ្ឋមន្ត្រីបានសម្រេច៖

៣.១- ឯកភាពបញ្ជូន «សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស» ទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីពិនិត្យនិងអនុម័ត ព្រមទាំងប្រគល់ភារកិច្ចជូនឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដូចខាងក្រោម៖

៣.១.១- សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី រៀបចំបន្តនីតិវិធីដើម្បីបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅស្ថាប័ននីតិប្បញ្ញត្តិ ពិនិត្យនិងអនុម័ត ដោយចាត់ទុកជាការប្រញាប់។

៣.១.២- ដឹកនាំសហការី អញ្ជើញទៅការពារសេចក្តីព្រាងច្បាប់នេះទាំងនៅរដ្ឋសភា និងព្រឹទ្ធសភា។

៣.២-ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ពង្រឹងកិច្ចការសេសសល់ ដើម្បីជំរុញឱ្យគម្រោងព្រែកជីកហ្វូណនតេជោ អាចត្រូវបានអនុវត្តដោយរលូន ជាពិសេស កម្មវិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោនៅ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ខាងមុខ។

៣.៣-ប្រគល់ភារកិច្ចជូនឯកឧត្តម **វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំនិងផ្សព្វផ្សាយសារាចររបស់រាជរដ្ឋាភិបាលស្តីពីការអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ជាប្រវត្តិសាស្ត្រនេះ។

៣.៤- ប្រគល់ភារកិច្ចជូនឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ព្រមទាំងរដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ផ្សព្វផ្សាយពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ឱ្យបានផុសផុលបំផុត ហើយទទួលបានការចូលរួមពីមហាជនទូទៅឱ្យបានកុះករ ទាំងតាមរយៈបណ្តាញទូរទស្សន៍ វិទ្យុ និងតាមបណ្តាញសង្គម។

៣.៥- ប្រគល់ភារកិច្ចជូន ឯកឧត្តម **ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តនានា ផ្សព្វផ្សាយនិងអនុវត្តចលនាអបអរសាទរ តាមរយៈការទូងស្គរ គោះជួង នៅតាមវត្តអារាម សាលារៀន និងតាមផ្ទះរបស់ប្រជាពលរដ្ឋ ព្រមទាំងរៀបចំឱ្យមានការប្រគុំតន្ត្រី និងការបាញ់កាំជ្រួចនៅតាមទីតាំងដែលអាចធ្វើបាន នាថ្ងៃបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ នេះ ឱ្យបានមហោឡារិកបំផុត។

៣.៦- ប្រគល់ភារកិច្ចជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដោះស្រាយផលប៉ះពាល់នៃគម្រោងព្រែកជីកហ្វូណនតេជោជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ប្រកបដោយសមធម៌ និងចំណេញផ្នែកសេដ្ឋកិច្ចនិងនយោបាយ។

៣.៧-ប្រគល់ភារកិច្ចជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវចាប់ផ្តើមគិតគូរលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់គម្រោងព្រែកជីកនេះ ដើម្បីធានាថា គម្រោងព្រែកជីកនេះនឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ហើយផ្តល់ប្រយោជន៍ឱ្យអស់ពីលទ្ធភាព។

៣.៨-ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ខ្ពស់លើការវាយតម្លៃការងារពាក់កណ្តាលឆ្នាំ២០២៤ ឱ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹត ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសកម្មភាពសម្រាប់ ឆ្នាំ២០២៥ ជាពិសេសក្នុងកិច្ចដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិលរបស់ខ្លួន។

៣.៩- ប្រគល់ភារកិច្ចជូនក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានតាមរាជធានី ខេត្ត ពង្រឹងការងាររបស់ខ្លួន ជាពិសេស ការយកចិត្តទុកដាក់ខ្ពស់ក្នុងការសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងស្នើជំរុញការរៀបចំរបាយការណ៍ ៦ខែ និងទិសដៅអនុវត្តបន្ត ដើម្បីត្រៀមសម្រាប់កិច្ចប្រជុំធមាសលើកដំបូង ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែកក្កដា ខាងមុខ។

៣.១០-ប្រគល់ភារកិច្ចជូនឯកឧត្តម **វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ផ្តើមបូកសរុបសមិទ្ធផលការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានតាមរាជធានី ខេត្ត រួមទាំងបញ្ហាប្រឈម និងអនុសាសន៍ឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យកិច្ចប្រជុំធមាសលើកដំបូង ដើរតួជាវេទិកាគោលនយោបាយដ៏មានប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហាសំខាន់ៗ ដែលបងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានកំពុងជួបប្រទះ ក៏ដូចជាជំនួយដល់ការរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងការចាត់វិធានការអន្តរាគមន៍ទាន់ពេល និងប្រកបដោយប្រសិទ្ធភាព។

៣.១១-ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ពង្រឹង និងពន្លឿនការវិភាគមុខងារ ស្របតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា (គ.វ.រ.) កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ កន្លងមក និងត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនលើការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ស្របតាមសារាចរលេខ០៨ សរ របស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤។

៣.១២-ប្រគល់ភារកិច្ចជូនឯកឧត្តម **ស្វាយ ស៊ីថា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការព័ត៌មាននិងសាធារណមតិ ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ផ្សព្វផ្សាយអំពីសមិទ្ធផលនៃវិស័យទេសចរណ៍ និងផលិតផលទេសចរណ៍ តាមរយៈការផលិតមាតិកាវីដេអូខ្លីៗ និងបទយកការណ៍ទាក់ទងនឹងសមិទ្ធផល និងផលិតផលទេសចរណ៍ឱ្យបានច្រើននិងប្រកបដោយភាពបុរេសកម្ម សំដៅទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

៣.១៣-ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានភាពបុរេសកម្មនៃការផលិតមាតិកាវីដេអូពាក់ព័ន្ធនឹងសមិទ្ធផលការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍរីកចម្រើនតាមវិស័យនីមួយៗ ឱ្យបានផុលផុសនៅក្នុងបណ្តាញសង្គមរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ដើម្បីឆ្លើយតបទៅនឹងការបំផុសព័ត៌មានអវិជ្ជមានបំភ្លៃការពិតនានា ជាពិសេស នៅតាមបណ្តាញសង្គម។

៣.១៤-ប្រគល់ភារកិច្ចជូនឯកឧត្តមបណ្ឌិត **ថោង ខុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងជាប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ រៀបចំកែសម្រួលគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរនិងលេខាធិការដ្ឋាន មកស្ថិតក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

៧ TP

ព្រមទាំងជំរុញការរៀបចំវិធានការនិងផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ សម្រាប់ឆ្នាំ ២០២៥ ឱ្យបានឆាប់។

៣.១៥-ប្រគល់ភារកិច្ចជូនឯកឧត្តមបណ្ឌិត **ថោង ខុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងជាប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ និងឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ត្រូវជំរុញកិច្ចសហការជាមួយវិស័យឯកជន ដើម្បីពន្លឿនការរៀបចំផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍សម្រាប់ឆមាសទី២ ឆ្នាំ២០២៤ ឱ្យបានឆាប់ ព្រមទាំងត្រៀមផែនការសម្រាប់ឆ្នាំ២០២៥ ដោយត្រូវរួមបញ្ចូលនូវផែនការសកម្មភាពទាក់ទាញទេសចរណ៍ក្នុងរដូវកាលភ្ញៀវទេសចរទាបនិងខ្ពស់ (Low and High Season)។

៣.១៦-ប្រគល់ភារកិច្ចជូនសមាជិករាជរដ្ឋាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមស្មារតីនៃសេចក្តីណែនាំលេខ០២ សណន របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីរបៀបរបបការងាររបស់រាជរដ្ឋាភិបាលក្នុងទំនាក់ទំនងជាមួយរដ្ឋសភា។

៣.១៧-ប្រគល់ភារកិច្ចជូន ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឯកឧត្តម **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហការពិនិត្យស្រាវជ្រាវលើបញ្ហាសារធាតុញៀនដែលផ្សំដោយថ្នាំពេទ្យ និងសារធាតុញៀនក្នុងបារីអេឡិចត្រូនិក ដើម្បីចាត់វិធានការទប់ស្កាត់និងបង្ក្រាបបានទាន់ពេលវេលា។

៣.១៨-ប្រគល់ភារកិច្ចជូន ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ បន្តរឹតបន្តឹងការអនុវត្តគោលនយោបាយ "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព" ដូចខាងក្រោម៖

៣.១៨.១-សហការជាមួយឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បង្កើនការយកចិត្តទុកដាក់ និងជំរុញការបង្ក្រាបបទល្មើសគ្រឿងញៀនជាប់ជាប្រចាំ ដើម្បីការពារសុខសុវត្ថិភាព និងបង្កើនសេចក្តីទុកចិត្តជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

៣.១៨.២-សហការជាមួយឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើការបញ្ជូនអ្នកញៀនគ្រឿងញៀនទៅមណ្ឌលស្តារនីតិសម្បទា ដើម្បីបន្សាប ព្យាបាល និងផ្តាច់ខ្លួនពីគ្រឿងញៀន ហើយវិលត្រឡប់ទៅក្នុងមូលដ្ឋានវិញ។

៣.១៨.៣-សហការជាមួយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា បន្តបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទជាប្រចាំ និងបញ្ឈប់ការផ្តល់អាជ្ញាបណ្ណល្បែងស៊ីសងថ្មីទៀតនៅតាមមូលដ្ឋាន។

៣.១៨.៤-បន្តយកចិត្តទុកដាក់ និងជំរុញការបង្ក្រាបក្មេងទំនើងនៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ដើម្បីធានារក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៅមូលដ្ឋាន ព្រមទាំងកាត់បន្ថយការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ អាណាព្យាបាល និងមាតាបិតា។

៣.១៩-ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី សហការពិនិត្យដាក់បញ្ចូលស្ត្រីជាពិរុទ្ធជនដែលមានផ្ទៃពោះ និងស្ត្រីជាពិរុទ្ធជនដែលមានកូននៅជាមួយក្នុងពន្ធនាគារ ទៅក្នុងផែនការនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**ចម្លងជូន៖**
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ